# មហាព្រះវេស្សន្តរជាតក (សង្ខេប)

## កណ្ឌមហាពន (ទី៧)

ជូជកោ      រីជូជកចាស់ជរាចូលដល់អាស្រមបរមសាលាក៏មានក្ដីសោមនស្ស ស្រស់ស្រាយ និយាយសួរសុខទុក្ខព្រះតាបស។

តាបសថា: អាត្មាឥតជម្ងឺតម្កាត់អ្វីទេ ព្រាហ្មណ៍អើយអ្នកមកអំពីទីឆ្ងាយសមក្ដៅក្រហាយ ចូរអញ្ជើញទៅផ្ទួតទឹកជម្រះកាយ បរិភោគផ្លែឈើទាំងឡាយតាមប្រាថ្នាចុះ ទុំៗនៃផ្លែឈើមានទម្ពាប់ ល្ពៅ បង្គៅ សិរមាន់ ច័ន្ទន៍ ម៉ាក់ប៉ែន ធុរេន គុយ ស្រគំ មានខ្ទិះ មានទុំ ចូរអ្នកបរិភោគតាមប្រាថ្នា។

ជូជកថា: ផលាផលខ្ញុំទទួលយកគ្រាន់តែបរិភោគប៉ុណ្ណោះ ព្រោះខ្ញុំឥតប្រាថ្នាការឯទៀតឡើយ ខ្ញុំមកនេះ ដើម្បីជួបនឹងព្រះ វេស្សន្តរតែមួយប៉ុណ្ណោះ។

តាបសសង្ស័យសួរថា: ក្រែងប្រស្នេងឯងមកសុំព្រះអគ្គមហេសី ឬព្រះរាជបុត្រាបុត្រីទេដឹង?

ជូជកប្រកែកថា: ទេ! ទេ! ទានប្រោសពុំមែនដូច្នោះទេ! ខ្ញុំនេះជាព្រាហ្មណ៍មានសីលសត្យា ដែលព្រះបាទស្រីសញ្ជ័យបានប្រើមកសួរសុខទុក្ខព្រះវេស្សន្តរ ព្រះគុណាជ្រាបលំនៅនៃព្រះវេស្សន្តរឬទេ?

តាបសថា: ស្គាល់ដែរ អើបើដូច្នោះ ហ៎បរិភោគឲ្យឆ្អែតឆ្អន់ ទៅចុះអាស្រ័យដំណេកនៅទីនេះសិនហើយ ព្រឹកឡើងសឹមយើងនឹងប្រាប់ផ្លូវឲ្យទៅ។

អច្ចុមហាឥសី មានជំនឿជឿពាក្យជូជកពោលកុហកដូច្នោះ ព្រឹកឡើយចង្អុលប្រាប់មាគ៌ាពណ៌នារាប់រៀបនូវឈើក្នុងព្រៃ នូវពួកបក្សី នូវហ្វូងត្រីក្នុងស្រះមុច្ចលិន្ទ ព្រមទាំងភូមិភាគទីបរិវេណ ជុំវិញអាស្រមបរមសាលានៃព្រះវេស្សន្តរ។

ជូជកមានអំណរ ក៏ថ្វាយបង្គំលាធ្វើប្រទក្សិណព្រះអច្ចុមហាឫសី៣ជុំ ហើយពុំលង់ឡើយ ក៏ដើរទៅតាមផ្លូវដែលព្រះមហាឥសីពណ៌នាប្រាប់ ប្រញាប់ចង់ឲ្យបានដល់អាស្រមបរមសាលាក្នុងថ្ងៃនោះឯងហោង។

**(ចប់ កណ្ឌទី៧ កណ្ឌមហាពន សូមរង់ចាំតាមដានកណ្ឌទី៨ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព